**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

* * *

# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១—អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៤០ អនក្រ.បក**

**ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យ**

**មន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍**

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើ ដោយព្រះរាជ ក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ តុលា ឆ្នាំ ១៩៩៥
- យោងតាមសភាពការណ៍ចាំបាច់

**សំរេច**

**មាត្រា ១** : មន្ត្រីរាជការទាំងពីរភេទ ដែលដល់អាយុ ៥៥ឆ្នាំ ត្រូវដាក់អោយចូលនិវត្តន៍ លើកលែងតែករណីដូចមានចែងក្នុងមាត្រា ២ ខាងក្រោម ÷

**មាត្រា ២** : ចាប់ពីពេលនេះរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ១៩៩៩ រាជរដ្ឋាភិបាលអាចអនុញ្ញាតអោយ អ្នករាជការដែលមានអាយុលើសពី ៥៥ឆ្នាំ បន្តធ្វើការងារ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការនូវអ្នកមានសមត្ថភាពខ្ពស់ និងមានបទពិសោធន៍ ។ ការអនុញ្ញាតពិសេសនេះត្រូវសំរេចដោយអនុក្រឹត្យ ។

**មាត្រា ៣** : មន្ត្រីរាជការស៊ីវិលដែលអាចសុំពន្យារពេលចូលនិវត្តន៍បាន ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ÷

- មន្ត្រីដែលមានកំរិតជំនាញបច្ចេកទេស ដែលក្រសួងស្ថាប័នត្រូវការជាចាំបាច់ ហើយពុំទាន់មានអ្នកជំនួស នៅឡើយ ។
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ អាចធានាបំរើការងារបន្តបាន ។
- មានស្មារតីខិតខំប្រឹងប្រែងបំពេញការងារ មានស្នាដៃល្អ ។
- មានកិរិយាមាយាទល្អ និង ស្អាតស្អំ ។
- មានសតិសម្បជញ្ញៈទទួលខុសត្រូវក្នុងកិច្ចការដែលបានទទួលបន្ទុក ។
- មានទំនាក់ទំនងល្អជាមួយសហសេវិក និងជាមួយមហាជន ។

**មាត្រា ៤** : ការស្នើសុំពន្យារពេលចូលនិវត្តន៍ ត្រូវមានសំណុំលិខិតដូចខាងក្រោម ÷

- លិខិតស្នើសុំពន្យារពេលចូលនិវត្តន៍របស់សាមីជន និងការវាយតម្លៃរបស់ប្រធានស្ថាប័នសាមីភ្ជាប់ជាមួយ។
- ជីវប្រវត្តិសង្ខេបរបស់សាមីជន ដោយមានបិទរូបថត និងមានការបញ្ជាក់ពីស្ថាប័នសាមី ។
- របាយការណ៍ផ្ទាល់ខ្លួន អំពីលក្ខណៈសម្បត្តិ ដូចមានចែងក្នុងមាត្រា ៣ ខាងលើ ព្រមទាំងមានការបញ្ជាក់ ត្រឹមត្រូវពីស្ថាប័នសាមី ។

**មាត្រា ៥** : ក្រសួងស្ថាប័ននីមួយៗ ត្រូវលើកសំណើពន្យារពេលចូលនិវត្តន៍នៃមន្ត្រីរាជការមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចំនួន ០១លើកក្នុង ០១ ឆ្នាំ គឺយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ ឧសភា នៃឆ្នាំនីមួយៗ នូវមន្ត្រីរាជការដែលស្នើសុំពន្យារពេលចូលនិវត្តន៍នៃឆ្នាំបន្ទាប់ ដែលរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈត្រូវធ្វើការបូកសរុប និងដាក់ជូនគណៈកម្មការពិនិត្យការសុំពន្យារពេលចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល ។

គណៈកម្មការពិនិត្យការសុំពន្យារពេលចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល ពិនិត្យនិងលើកសំណើតាមនីតិវិធី ដើម្បីសុំការសំរេចតាមរយៈអនុក្រឹត្យ ។

**មាត្រា ៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ១៨២ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ